# ស្ថានភាពអតិផរណានៅខែមេសា ឆ្នាំ២០១៩

## ក. អតិផរណាក្នុងប្រទេស

តាមប្រភពទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ (NIS) បានបង្ហាញថា នៅខែមេសា ឆ្នាំ២០១៩នេះ ជារួម សន្ទស្សន៍ថ្លៃទំនិញនិងសេវាប្រើប្រាស់គ្រប់មុខនៅរាជធានីភ្នំពេញ ***មានការកើនឡើងប្រមាណ ០,៣% ធៀបនឹងខែមុន*** ។ សន្ទស្សន៍ថ្លៃក្រុមទំនិញ និងសេវា ស្ទើរតែទាំងអស់ មានការប្រែប្រួលបន្តិចបន្តួច ជាពិសេស សន្ទស្សន៍ថ្លៃទំនិញ ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត (កើន ០,១%) គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ (កើន ០,១%) សុខាភិបាល (កើន ០,០២%) អាហារ ភេសជ្ជៈមិនមែនជាតិស្រវឹង (កើន ០,៦%) ទំនិញ និងសេវាដឹកជញ្ជូន (កើន ១,៥%) បើធៀបនឹងខែមីនាកន្លងទៅ។ រីឯសន្ទស្សន៍ថ្លៃនៃក្រុមមុខទំនិញ និងសេវាមួយចំនួនមានការថយចុះ ជាពិសេស ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ (-០,១%) គមនាគមន៍ (-០,២%) និងភោជនីយដ្ឋាន (-១,៥%) បើធៀបនឹងខែមីនាកន្លងទៅ។

ក្នុងខែមេសា ឆ្នាំ២០១៩ សន្ទស្សន៍ថ្លៃទំនិញនិងសេវាប្រើប្រាស់គ្រប់មុខនៅរាជធានីភ្នំពេញ មានកំណើន ***២,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន*** ជាពិសេស ក្រុមទំនិញភោជនីយដ្ឋាន (កើន ៦,៦%) ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ (កើន ៥,០%) សម្លៀកបំពាក់ និងស្បែកជើង (កើន ៣,៤%) ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈ (កើន ១,៩%) និងគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ (កើន ១,៥%)។ រីឯ សន្ទស្សន៍ថ្លៃក្រុមទំនិញនិងសេវាដឹកជញ្ជូន នៅតែបន្តធ្លាក់ចុះ (-០,៨%) បើធៀបនឹង ខែដូចគ្នា ឆ្នាំមុន ដោយសារតែការធ្លាក់ចុះនៃ ប្រេងសាំងធម្មតា ម៉ាស៊ូត និង សេវាដឹកជញ្ជូន ។

***តាមការធ្វើចំណោលដល់ខែ៤ ឆ្នាំ២០១៩ អត្រាអតិផរណាឆ្នាំលើឆ្នាំ (year on year) និងអតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ២,៩% និង ២,១% រៀងគ្នា។*** នៅឆ្នាំ២០១៩នេះ ស្ថានភាពអតិផរណានៅតែស្ថិតក្នុងរង្វង់ក្រោម ៥% ដោយសារតែ i) ស្ថិរភាពថ្លៃមុខទំនិញប្រើប្រាស់ (consumption goods) ជាពិសេស ម្ហូបអាហារនៅលើទីផ្សារ, ii) ការឧបត្ថម្ភធនលើប្រេងឥន្ធនៈពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរក្សាស្ថិរភាពថ្លៃប្រេងសាំង និង iii) ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលធ្វើឱ្យកំណើនអតិផរណាស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ។

| តារាង ១ ÷ ការប្រែប្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ ក្រុម មានដូចខាងក្រោម÷ | | |
|---|---|---|
| | ធៀបនឹងខែមុន (%) | ធៀបនឹងឆ្នាំមុន (%) |
| **មុខទំនិញគ្រប់មុខ** | **+០,៣** | **+២,១** |
| ១-អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | +០,៦ | +១,៩ |
| ២-ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | -០,១ | +៥,០ |
| ៣-សម្លៀកបំពាក់ និងស្បែកជើង | +០,២ | +៣,៤ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | +០,១ | +១,៩ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | +០,១ | +១,៥ |
| ៦-សុខាភិបាល | ០,០ | +១,៥ |
| ៧-ការដឹកជញ្ជូន | +១,៥ | -០,៨ |
| ៨-គមនាគមន៍ | +១,៥ | -០,៦ |
| ៩-ការកំសាន្ត និងវប្បធម៌ | +០,១ | +០,៦ |
| ១០-ការសិក្សា | ០,០ | ០,០ |
| ១១-ភោជនីយដ្ឋាន | -១,៥ | +៦,៦ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +០,១ | +១,១ |

| តារាងបម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន (%) | | | | ធៀបនឹងឆ្នាំមុន (%) | | | |
| | ២០១៩ | | | | ២០១៩ | | | |
| | មករា | កុម្ភៈ | មីនា | មេសា | មករា | កុម្ភៈ | មីនា | មេសា |
| អង្ករ | +០,២ | +០,៦ | ០,០ | +០,៤ | +២,៦ | +២,៩ | +២,៧ | +៣,០ |
| សាច់គោ | +០,៤ | +០,២ | ០,០ | +០,២ | +២,១ | +១,៦ | +១,៧ | +១,១ |
| សាច់មាន់ | +០,៥ | ០,០ | +០,៥ | +០,៣ | +៤,០ | +២,៩ | +៤,២ | +៣,៥ |
| សាច់ទា | +០,៦ | +០,៦ | ០,០ | +០,៤ | +២,២ | +៣,០ | +៣,១ | +៣,០ |
| សាច់ជ្រូក | +០,៧ | +០,៦ | -០,៦ | +២,១ | +១,៧ | +២,០ | +០,៨ | +២,៤ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +០,២ | +០,២ | ០,០ | +០,៧ | +២,៦ | +២,៤ | +២,២ | +២,៣ |
| ក្នុងនោះត្រីស្រស់ | ០,០ | ០,០ | ០,០ | +០,៧ | +២,០ | +១,៦ | +១,៣ | +១,៤ |
| ផ្លែឈើ | -០,៧ | +១,៣ | +០,២ | -០,៣ | +១,៧ | +១,២ | +១,៤ | -០,៦ |
| ផ្លែឈើស្រស់ | -០,៦ | +១,៤ | +០,៤ | -០,៤ | +១,៦ | +១,២ | +១,៦ | -០,៨ |
| បន្លែ | -១,០ | +១,៤ | -០,៦ | +១,១ | +២,៧ | +៣,៩ | +៣,០ | +២,៧ |
| បន្លែជាស្លឹក | -១,១ | +១,៤ | -០,៤ | +០,៩ | +៥,១ | +៦,៥ | +៥,២ | +៤.៧ |
| បន្លែជាផ្លែ | -១,៥ | +២,២ | -១,១ | +២,៣ | +២,៣ | +៣,៨ | +២,២ | +២,៦ |

## ២. អតិផរណាប្រចាំឆ្នាំតាមបណ្តាប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | |
|---|---|---|---|---|---|
| ប្រទេស | ២០១៨ | ២០១៩ | | | |
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា |
| ប្រទេសកម្ពុជា | +១,៦ | +១,៥ | +២,០ | +២,២ | +២,១ |
| ប្រទេសវៀតណាម | +៣,០ | +២,៦ | +២,៦ | +២,៧ | +២,៩ |
| ប្រទេសថៃ | +០,៤ | +០,៣ | +០,៧ | +១,២ | +១,២ |
| ប្រទេសម៉ាឡេស៊ី | +០,២ | -០,៧ | -០.៤ | +០,២ | +០,២ |
| ប្រទេសឥណ្ឌូនេស៊ី | +៣,១ | +២,៨ | +២,៦ | +២,៥ | +២,៨ |
| ប្រទេសហ្វីលីពីន | +៥,១ | +៤,៤ | +៣,៨ | +៣,៣ | +៣,០ |
| ប្រទេសចិន | +១,៩ | +១,៧ | +១,៥ | +២,៣ | +២,៥ |
| ប្រទេសកូរ៉េខាងត្បូង | +១,៣ | +០,៨ | +០,៥ | +០,៤ | +០,៦ |
| ប្រទេសជប៉ុន | +០,៣ | +០,២ | +០,២ | +០,៥ | +០,៩ |

ប្រភពទិន្នន័យ
(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)